**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៦២២ សសរ

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២០

# ជម្រាបជូន

- **ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សារាជធានី ខេត្ត**
- **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ** ៖ ស្តីពីការពង្រឹងការគ្រប់គ្រងការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**យោង** ៖
- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- សេចក្តីសម្រេចលេខ១០០២៩ សសរ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការដាក់ឱ្យប្រើសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ និងលោក លោកស្រី** ជ្រាបថា នាចុងឆ្នាំ២០១៩កន្លងមកនេះ រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍រដ្ឋបាលឯកភាព ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

នៅដើមឆ្នាំ២០២០នេះ គ.ជ.អ.ប បានដាក់ចេញនូវសេចក្តីសម្រេចដើម្បីសមាហរណកម្មបុគ្គលិកនៃការិយាល័យជំនាញទាំងអស់របស់ក្រសួងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចូលទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌរួចរាល់អស់ហើយ។ ទន្ទឹមគ្នានេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសក៏បានប្រកាសដាក់ឱ្យដំណើរការអនុវត្តតាមមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់ខ្លួនផងដែរ។ ក្នុងន័យនេះ

រដ្ឋបាលក្រុង ស្រុកត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ហើយរដ្ឋបាលខណ្ឌត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងចំពោះរដ្ឋបាលរាជធានីភ្នំពេញក្នុងការបំពេញតួនាទី ភារកិច្ច និងការអនុវត្តមុខងារនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រធានការិយាល័យ និងប្រធានអង្គភាពនានាក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (នាយករដ្ឋបាល គណៈអភិបាល និងក្រុមប្រឹក្សា) ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យដូចបានចុះយោងខាងលើ។

នាពេលថ្មីៗនេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា មន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត និងការិយាល័យ អង្គភាពមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (អតីតការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ) នៅតែបន្តទំនាក់ទំនងការងារតាមរយៈលិខិតរដ្ឋបាលផ្លូវការជាមួយគ្នាតាមប្រព័ន្ធចាស់ ដោយមិនបានឆ្លងកាត់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗឡើយ។ ការធ្វើទំនាក់ទំនងការងារបែបនេះ គឺពុំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ខ្សែគណនេយ្យភាព គោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងតាមរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដែលធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំអាចគ្រប់គ្រងបានលើការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលរបស់ខ្លួនបានឡើយ។

ដើម្បីពង្រឹងការគ្រប់គ្រង និងការចាត់ចែងការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាពស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមហាផ្ទៃសូមផ្តល់ការណែនាំបន្ថែមនូវគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

- រាល់លិខិតរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ធ្វើទំនាក់ទំនងការងារទៅស្ថាប័នខាងក្រៅ រួមមាន៖ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិដទៃទៀត ព្រមទាំងស្ថាប័នមិនមែនរដ្ឋ ត្រូវពិនិត្យ សម្រេច និងចុះហត្ថលេខាដោយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្អែកតាមការកំណត់ដោយលិខិតបទដ្ឋានជាធរមាន ដោយត្រូវប្រើប្រាស់ត្រា និងចុះលេខលិខិតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ
- អភិបាលក្រុង ស្រុក ខណ្ឌអាចប្រគល់សិទ្ធិក្នុងការពិនិត្យសម្រេច និងចុះហត្ថលេខាលើលិខិតរដ្ឋបាលមួយចំនួនដល់អភិបាលរង ឬនាយករដ្ឋបាលតាមការចាំបាច់ ដោយប្រើប្រាស់ទម្រង់លិខិត ត្រា និងការចុះលេខលិខិតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ប្រធានការិយាល័យ ឬប្រធានអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំមានសិទ្ធិក្នុងការសម្រេច និងចុះហត្ថលេខាលើលិខិតរដ្ឋបាលណាមួយក្នុងនាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើទំនាក់ទំនងការងារទៅស្ថាប័នខាងក្រៅបានឡើយ
- ប្រធានការិយាល័យ ឬប្រធានអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចធ្វើទំនាក់ទំនងការងារផ្ទៃក្នុងតាមរយៈលិខិតរដ្ឋបាល (ក្នុងចំណោមការិយាល័យ និងអង្គភាពនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រវាងការិយាល័យ ឬអង្គភាពជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង

រវាងការិយាល័យជាមួយអង្គភាពក្រោមឱវាទ) និងមានសិទ្ធិពិនិត្យ និងចុះហត្ថលេខាលើទម្រង់បែបបទ នៃការផ្តល់សេវារដ្ឋបាលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសតាមតួនាទី ភារកិច្ចរបស់ខ្លួន

- ដើម្បីធានាដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋបានឆាប់រហ័ស និងទាន់ពេលវេលា អភិបាលក្រុង ស្រុក ខណ្ឌត្រូវកំណត់ក្របខណ្ឌពេលវេលាជាក់លាក់សម្រាប់ការពិនិត្យ សម្រេច និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងប្រភេទសេវានីមួយៗដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ។ អភិបាល និងថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌដែលបានទទួលសិទ្ធិក្នុងការពិនិត្យសម្រេច និងចុះហត្ថលេខាលើឯកសារទាំងនេះ ត្រូវអនុវត្តតាមក្របខណ្ឌពេលវេលាដែលបានកំណត់ឱ្យបានម៉ឺងម៉ាត់។

ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងមហាផ្ទៃស្នើអភិបាលរាជធានី ខេត្តធ្វើការផ្សព្វផ្សាយ និងណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធនានាថា រាល់ការធ្វើទំនាក់ទំនងការងារក្នុងវិស័យបច្ចេកទេសរបស់ខ្លួនជាមួយការិយាល័យ ឬអង្គភាពនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើឡើងតាមរយៈលិខិតរដ្ឋបាលផ្លូវការទៅអភិបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗដោយផ្ទាល់ដើម្បីដឹកនាំ ចាត់ចែង និងអនុវត្ត មិនមែនទំនាក់ទំនងទៅការិយាល័យដោយផ្ទាល់ដូចមុននោះឡើយ។ ទន្ទឹមនេះ អភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងកែតម្រូវនូវរាល់លិខិតណែនាំដែលបានដាក់ចេញដោយរដ្ឋបាលរាជធានី ខេត្តនាពេលកន្លងមក ឱ្យមានខ្លឹមសារស្របតាមគោលការណ៍ខាងលើនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារ-កាលប្បវត្តិ